# សករាជដែលខ្មែរប្រើ

មកទល់ថ្ងៃនេះ ខ្មែរប្រើសករាជចំនួន៤ គឺមហាសករាជ ពុទ្ធសករាជ ចុល្លសករាជ និងគ្រិស្តសករាជ។ សករាជដែលប្រើដំបូងគេគឺ "ឝក" ត្រូវនឹងបច្ចុប្បន្នថា "មហាសករាជ"។ កាលបរិច្ឆេទដែលចាស់ជាងគេមាននៅក្នុងសិលាចារឹកទួលវត្តគំនូរ(K.600) ស្រុកអង្គរបុរី ខេត្តតាកែវ។ សិលាចារឹកចារថា [...**ត្រៃត្រីគោត្តរបញ្ចឝតឝកបរិគ្រហ ត្រយោទឝីកេត**...] ដែលមានសេចក្ដីថា "ឆ្នាំ៥៣៣សក:(មហាសករាជ) ១៣កើត"។ បើតាមទិន្នន័យសិលាចារឹកខ្មែរនៅក្នុងសម័យមុនអង្គរនិងសម័យអង្គរ ខ្មែរប្រើសករាជតែមួយគត់គឺ "**ឝក**" ដែលត្រូវគ្នានឹងពាក្យ "**មហាសករាជ**" ពេលបច្ចុប្បន្ន។

តាមរយ:សិលាចារឹកដែលបានចុះបញ្ជីកន្លងមក យើងប្រទះឃើញពាក្យ "**មហាសករាជ**" តែម្ដងគត់នៅក្នុងសិលាចារឹកវត្តតាំងផ្លូក(K.746) ខេត្តកំពង់ចាម ដែលចារថា [(១)សព្ពមសម្ពុព្រះពុទ្ធសក្រាចព្រះសាសណា (២)អតិកន្តាកន្លោងទៅវហេិ្យបាន ២៤៣១ព្រះ(៣)វសា**មហាក្ខរាជ**លើងប្ញា១៨១០ចុលសក្ខរាជ១២៥០ (៤)ឆ្នាំមជូតនខ្សត្រសំវេិទ្ធិក្ខគឹម្ហន្តរតូវខែពីសាក...]។ កាលបរិច្ឆេទដែលមានប្រើពាក្យ "**មហាសករាជ**" នេះ មានអាយុតិចជាងកាសប្រាក់របស់ព្រះបាទអង្គដួងដែលបោះក្រោយឆ្នាំ១៨៥០ ប៉ុន្តែនៅលើកាសប្រាក់នោះចុះកាលបរិច្ឆេទឡើងគ្រងរាជ្យសម្បត្តិរបស់ទ្រង់។ លើកាសនោះបង្ហាញកាលបរិច្ឆេទព្រះសករាជ២៣៩០(ព.ស.) មហាសករាជ១៧៦៩ ចុល្លសក្ខរាជ១២០៩ ឆ្នាំមមែ នព្វស័ក ថ្ងៃចន្ទ ២កើត ខែផល្គុន។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺពាក្យ "**សករាជ**" ដែលធ្លាប់តែសម្គាល់ឆ្នាំជា **ចុល្លសករាជ** ដូចក្នុងសិលាចារឹកវត្តរំលក(K.27:5, 11, 18) និង **មហាសករាជ** ដូចក្នុងសិលាចារឹកអង្គរវត្តនានាកាលពីមុន នៅក្នុងកាក់នេះបែបជាមកសម្គាល់ពុទ្ធសករាជទៅវិញ។ "**ឝក**" ឬ "**មហាសករាជ**" កើតក្រោយគ្រិស្តសករាជចំនួន៧៨ឆ្នាំ ដូច្នេះបើនឹងរកឆ្នាំមហាសករាជមកជាគ្រិស្តសករាជ ត្រូវបូកឆ្នាំមហាសករាជនិង៧៨។

បើគិតពីការប្រើពុទ្ធសករាជវិញ ទោះបីជាខ្មែរចាប់ផ្ដើមកាន់ពុទ្ធសាសនាថេរវាទនៅក្នុងរាជ្យព្រះបាទស្រិន្ទ្រវម៌្មក៏ដោយ ពេលនោះខ្មែរពុំទាន់ប្រើពុទ្ធសករាជនៅឡើយទេ

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

គឺនៅប្រើមហាសករាជដដែល។ យើងមានសិលាចារឹកគោកស្វាយចេក(K.745) ដែលជាសិលាចារឹកភាសាបាលីថេរវាទចាស់ជាងគេ និងជាសិលាចារឹករបស់ព្រះបាទស្រីន្ទ្រវម៌្ម ដែលជាក្សត្រកាន់ពុទ្ធសាសនាថេរវាទមុនគេក្នុងប្រវត្តិសាស្ត្រខ្មែរជាភស្តុតាង ដូចមានឃ្លាថា [... **១២៣០គក នវមីកេត បុប្យ អាទិត្យវារ អគ្វិនីនក្សត្រ បាទវ្យតិស្រចត្ថុតិយ គិនុវ្រះករុណាតបរមបវិត្រវ្រះបាទកម្រតេងអញគ្រីគ្រីន្ទ្រវម៌្មទេវ ប្រេចារគិលាប្រសម្ដកតគិស្រុកអំវៅស្រុកចុងធ្និង...**] ដែលប្រែសម្រួលជាខ្មែរទំនើបថា "ឆ្នាំ១២៣០សក: ៩កើត ខែបុស្ស ថ្ងៃអាទិត្យ អស្វិនីនក្សត្រ(ឆ្នាំមមី) (វេលា)បាទពីរផុតយាមទី៣។ ព្រះករុណាដ៏បរមបពិត្រព្រះបាទស្រីស្រីន្ទ្រវម៌្មទេវ: បានបញ្ជាឱ្យចារឹកព្រះរាជសាសន៍លើសិលា(អំពី)ដើមទងភូមិអំពៅនិងភូមិចុងស្និង..."។ សិលាចារឹករបស់ព្រះអង្គនៅឯប្រាសាទបន្ទាយស្រី(K.569) ក៏ចារជាឆ្នាំមហាសករាជដែរ គឺនៅឆ្នាំ១២២៨សក:។ នាសម័យលង្វែក ខ្មែរនៅតែបន្តប្រើមហាសករាជដដែល ដូចមានភស្តុតាងសិលាចារឹករបស់ព្រះរាជមាតាសុជាតា(K.303) ចារថា [...**លុះជាតតល្វូនេះមន្គិលុះត១៤៩៩សក ធ្នូនក្សត្រ ចតុទ្ទំគិកេត អាសាឍ្យ សោពារ**...] មានសេចក្ដីថា "លុះជាតិឥឡូវនេះ គឺមកដល់ឆ្នាំ១៤៩៩សក: ឆ្នាំធ្នូវ ទី១៤កើត ខែអាសាធ ថ្ងៃសៅរ៍"។ សិលាចារឹកនៅសម័យកណ្ដាល ជាពិសេសក្នុងក្រុមសិលាចារឹកនគរវត្ត(IMA) មានចារឹកឆ្នាំសុទ្ធតែមហាសករាជ បើទោះជាពេលនោះខ្មែរបានកាន់ពុទ្ធសាសនាប្រហែលជាង៤០០ឆ្នាំទៅហើយក្ដី ប៉ុន្តែខ្មែរនៅតែប្រើមហាសករាជ ខ្មែរមិនបានប្រើពុទ្ធសករាជទេនៅពេលនោះ[1]។

បើយើងមើលការចាប់ផ្ដើមគិតឆ្នាំជាពុទ្ធសករាជវិញ គឺយើងឃើញមានប្រើព្រមគ្នាជាមួយកាលបរិច្ឆេទចុល្លសករាជ ដែលមានក្នុងសិលាចារឹកវត្តរំលក(K.27) នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ កាលបរិច្ឆេទជាឆ្នាំពុទ្ធសករាជនោះ ចារជាភាសាបាលីសុទ្ធថា [... **សិរីសាក្យមុនិ សព្វញ្ញុពុទ្ធស្ស បរិនីព្វានទិវសតោបត្ថាយ ចតុទិន្ន ចតុមាស្ស ឯកុនតឹង្សាឯកសតសំវច្ឆរ សតាទិកានី ទ្វេសំវច្ឆរ សហស្សានីអតីកន្តានី អហេសុំ**...] មានសេចក្ដីប្រែសម្រួលថា "ចាប់តាំងពីថ្ងៃដែលព្រះសិរីសាក្យមុនី ព្រះសព្វញ្ញូពុទ្ធដ៏មានយស ទ្រង់យាង

[1] នង ម៉ានី, ២០១២។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ចូលបរិនិព្វាន បានអតិកន្តារកន្លងទៅចំនួន ពីរពាន់មួយរយម្ភៃប្រាំបួនឆ្នាំ បួនខែ និងបួនថ្ងៃ...”[2]។ ចំណែកឯការប្រើប្រាស់ពុទ្ធសករាជក្នុងសិលាចារឹកភាសាខ្មែរវិញ យើងឃើញដំបូងគេតាមរយៈសិលាចារឹកវត្តតាឡោក(K.746) ដូចមានសេចក្ដីចារថា [...**ព្រះពុទសក្រាជបានពីរ(ពាន)បួនរយវស្សា**...]។ បើយើងគិតពីគម្លាត ដែលយើងឃើញការគិតឬសញ្ញាណដំបូង នៃការគិតកាលបរិច្ឆេទជាពុទ្ធសករាជ ដែលមានក្នុងសិលាចារឹកវត្តរំលក និងសិលាចារឹកវត្តតាឡោក គឺឆ្ងាយគ្នាណាស់ដែរ។ ព្រះពុទ្ធសករាជកើតមុនគ្រិស្តសករាជចំនួន៥៤៣ឆ្នាំ បើចង់គិតពុទ្ធសករាជមកជាគ្រិស្តសករាជ ត្រូវដកពុទ្ធសករាជនិង៥៤៣។

ចំណែកឯ **ចុល្វសករាជ** វិញឃើញមានចារដំបូងក្នុងសិលាចារឹកវត្តរំលក នៅក្នុងផ្នែកភាសាខ្មែរដូចមានសេចក្ដីថា [...**ឰតក្វាពីស្វាអារាម្ម៌នេះ កុនក្សត្រសករាជឆ្នា៩៤៩ គ្រាសើកព្រះនរេស្ស**...] ប្រែសម្រួលថា “រីឯកាលពីពេលសាងសង់វត្តអារាមនេះនៅឆ្នាំកុរ (ចុល្វ)សករាជ៩៤៩ នៅគ្រាសឹកសង្គ្រាមរបស់ព្រះនរេស្ស...”។ **ចុល្វសករាជ** កើតក្រោយគ្រិស្តសករាជចំនួន៦៣៨ឆ្នាំ។ **ចុល្វសករាជ** មានន័យថាសករាជតូច ផ្ទុយនឹងមហាសករាជ ជាសករាជធំ។

តាំងតែពីដើមមក គេប្រើតែ “**ឝក**(សក)” តែមួយ គឺគ្រប់គ្រាន់ហើយ ប៉ុន្តែតាំងពីមានចុល្វសករាជ ពុទ្ធសករាជ និងគ្រិស្តសករាជមក ឆ្នាំ“**ឝក**(សក)” បានប្ដូរជា “មហាសករាជ” ដើម្បីកុំឱ្យច្រឡំជាមួយសករាជដទៃទៀត។ ដូចក្នុងករណីសិលាចារឹកវត្តរំលក ដូច្នេះដែរ កាលបរិច្ឆេទជាចុល្វសករាជ គេសរសេរត្រឹមតែ “សករាជឆ្នា៩៤៩” ប៉ុណ្ណោះ។ យើងឃើញមានប្រើពាក្យ “ចុល្វសករាជ” នេះម្ដងទៀតនៅក្នុងសិលាចារឹកវត្តតាំងធ្វកដូចបានបង្ហាញខាងលើត្រង់បរិយាយអំពីមហាសករាជ។

ទាំងការប្រើពុទ្ធសករាជនិងចុល្វសករាជ គឺយើងឃើញមានប្រើនៅក្នុងសិលាចារឹកវត្តរំលក ដែលជាសិលាចារឹកមានឥទ្ធិពលពីសៀម ទាំងសំណេរនិងការប្រើប្រាស់ចុល្វសករាជ ដែលពេញនិយមប្រើប្រាស់ខ្លាំងជាងគេនៅស្រុកសៀម[3]។ លោកបណ្ឌិត វង់

---

[2] វង់ សុធារ៉ា, ២០១២។

[3] សូមអាន វង់ សុធារ៉ា, ២០១២ :១៥៧-១៦៦។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

សុធារ៉ា បានអះអាងថា "ម៉្ងោះហើយ យើងគិតថាសិលាចារឹកនេះ(សិលាចារឹកវត្តរំលក) ទំនងជាសរសេរក្នុងរាជ្យព្រះបាទស្រីសុរិយោពម៌្ម ឬព្រះបាទជយជេដ្ឋាទី២ ដែលធ្លាប់រស់នៅស្រុកសៀមយ៉ាងយូរនោះឯង"[4]។ យើងគួរពិចារណាមើលលើគម្ងាតនៃការប្រើប្រាស់ពុទ្ធសករាជនិងចុល្ល‌សករាជដែលដាច់គ្នាយូរ រួចទើបចាប់ផ្តើមឃើញមានម្តងទៀតចាប់ពីរាជ្យព្រះបាទអង្គដួង ដែលបន្ទាប់មកក៏ចាប់ផ្តើមរីកសាយភាយ ដូចមានឃើញក្នុងកាសប្រាក់ សិលាចារឹកវត្តតាំងធ្វូក ច្បាប់ក្រមនានាដែលបោះពុម្ពផ្សាយនៅឆ្នាំ១៨៩១ និងបន្តមកដល់រាជ្យព្រះករុណាស៊ីសុវត្ថិជាដើម។ ដែលយល់ថាចាប់រីកសាយភាពបែបនេះ ដ្បិតយើងគ្រប់គ្នាដឹងថាព្រះអង្គដួងជាក្សត្រ ដែលយកចិត្តទុកដាក់លើវិស័យអក្សរសាស្ត្រជាតិនាជំនាន់នោះ។ ប៉ុន្តែចំណុចមួយទៀតដែលគួរនឹងពិនិត្យមើលឱ្យវែងឆ្ងាយ ដើម្បីឱ្យជ្រះស្រឡះក្នុងចិត្តនោះគឺថា តើការប្រើប្រាស់នេះជាឥទ្ធិពលមកពីសៀមឬទេ? ព្រោះទ្រង់ជាក្សត្រទទួលបានការអប់រំច្រើនពីស្រុកសៀម ឯព្រះសង្ឃសំខាន់ៗនៅកម្ពុជានាជំនាន់មុនក៏សុទ្ធតែបានឆ្លងកាត់ការរៀនសូត្រនៅស្រុកសៀមដូចគ្នា។

**បញ្ជីរូបភាព**



សិលាចារឹកទួលវត្តគំនូរ K.600

[4] វង់ សុធារ៉ា ២០១២។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



n. 943-A / K. 746

សិលាចារឹកវត្តតាំងធ្លក K.746



សិលាចារឹកវត្តវត្តរំលក K.27

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



កាសប្រាក់

## ឯកសារយោង


នង ម៉ានី

២០១២, អត្ថន័យនៃកាលបរិច្ឆេទក្នុងសិលាចារឹកប្រទេសកម្ពុជា, សារណាបរិញ្ញាបត្របុរាណវិទ្យា។

វង់ សុផាព់

២០១២, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្ដាល, ភ្នំពេញ, នគរវត្ត។